# មេរៀនទី ១៣៣៖ ព្រះបានអត់ទោសឲ្យដាវីឌ

## ២សាំយូអែល ១២៖១-៧, ទំនុកតម្កើង ៥១៖១- ១២

**មេរៀនសម្រាប់គ្រូ**( *យូធូបលីង* )៖ https://youtu.be/m6p1h7V3F8U

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/WkJJHQrmQcE

**គោលបំណង៖** ព្រះទទួលយកការប្រែចិត្តរបស់យើង។

**ខគម្ពីរចងចាំ៖** ទំនុកតម្កើង ៥១៖១០ *"ឱព្រះអង្គអើយ សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំ ហើយកែវិញ្ញាណក្នុងទូលបង្គំឲ្យត្រឹមត្រូវឡើង។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ចូរប្រយ័ត្ននឹងភ្នែកតូចអ្នក https://youtu.be/leoAGL9usF0
២. នៅរស់ https://youtu.be/NGQXTg3Uogg
៣. ខ្ញុំដឹងខ្លួនហើយ https://youtu.be/cNotISrjHI0

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «លើ ក្រោម ដំ»



១.ឲ្យកុមារឈរ២នាក់ទល់មុខគ្នាដោយក្តាប់ដៃ ដាក់ឆ្លាស់គ្នាលើក្រោម
២.គ្រូជាអ្នកស្រែក"លើក្រោមដំ"កុមារដែលមានដៃនៅខាងលើគេត្រូវព្យាយាមដំដៃដៃគូរបស់គេបើកុមារដំចំដៃរបស់ដៃគូកុមារនោះជាអ្នកឈ្នះ កុមារដែលមានដៃនៅខាងក្រោមត្រូវដកដៃអោយលឿននៅពេលលឺពាក្យ ថា"ដំ"។
៣. តាមរយៈល្បែងនេះបានបង្ហាញថា ការប្រុងប្រយ័ត្ននឹងមិននាំឲ្យយើងអន្តរាយ ដូចជាសាច់រឿងយើងនៅថ្ងៃនេះ។

### ៤. ការណែនាំមេរៀន

តើមានប្អូនៗប៉ុន្មាននាក់ធ្លាប់ជេគេខ្លះ? ចុះតើមានប្អូនៗណាខ្លះត្រូវបានគេជេ? តើការជេជាការល្អឬអាក្រក់? បាទ/ចាស ការជេអត់ល្អទេ។ ប្រសិនបើមានគេជេប្អូន តើប្អូនសើចឬក៏ខឹង? តើការជេជាអំពើបាបដែរឬទេ? បាទ/ចាស វាគឺជាអំពើបាប។ តើអំពើបាបមានអ្វីខ្លះ? នៅពេលដែលប្អូន លួចគេ ជេគេ វ៉ៃគេ កុហកគេ ស្អប់គេ សំលាប់គេ អញ្ចឹងអំពើបាបជាការគិតខុស និយាយខុស និងធ្វើខុស ដែលព្រះមិនសព្វព្រះហឫទ័យ។ យើងត្រូវសារភាពអំពើបាបរបស់យើងចំពោះព្រះ ហើយប្រែចិត្ត។ ការប្រែចិត្តមានន័យថា សុំការអភ័យទោសពីព្រះ ហើយងាកចេញពីអំពើបាប។ ថ្ងៃនេះ យើងនឹងរៀនអំពីស្តេច ដាវីឌ ដែលបានធ្វើបាបទាស់នឹងព្រះ និងការប្រែចិត្តរបស់គាត់។ តើអ្នកគិតថាព្រះនឹងអត់ទោសឱ្យ គាត់ដែរឬទេ?

### ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយហោរាណាថាន់បានទៅសួរសុខទុក្ខស្តេចដាវីឌ។ សូមចាំថាហោរា គឺជាអ្នកនាំសាររបស់ព្រះ។ ព្រះបានផ្តល់ព្រះបន្ទូលដល់ហោរាដើម្បីឲ្យអ្នកដទៃទៀតបានឮដែរ។ ណាថាន់បានចាប់ផ្តើមចែកចាយសាររបស់ព្រះ ដោយការនិទានរឿងមួយ។

គាត់បានប្រាប់អំពីបុរសអ្នកមានម្នាក់ ដែលគាត់មានអ្វីៗគ្រប់យ៉ាង រួមទាំងចៀមនិងគោជាច្រើនផងដែរ។ គាត់ក៏បាននិយាយអំពីបុរសក្រីក្រម្នាក់ដែលគាត់មានតែចៀមតូចមួយប៉ុណ្ណោះ។ បុរសក្រីក្រនោះស្រលាញ់កូនចៀមនោះខ្លាំងណាស់ ហើយចាត់ទុកវាដូចជាសត្វចិញ្ចឹម។ ថ្ងៃមួយ អ្នកដំណើរម្នាក់បានទៅលេងផ្ទះរបស់បុរសអ្នកមាននោះ។ ជាធម្មតាអ្នកមានត្រូវរៀបចំអាហារសម្រាប់ភ្ញៀវរបស់គាត់ ប៉ុន្តែជំនួសឱ្យការប្រើសត្វ ដែលគាត់ចិញ្ចឹម គាត់បានលួចចៀមតែមួយរបស់បុរសក្រីក្រនោះ។

ដាវីឌបានគិតថាវាជាការអយុត្តិធម៌ ដែលបុរសអ្នកមានយកចៀមរបស់អ្នកក្រនោះ។ ពេលនោះដាវីឌគាត់ខឹងណាស់! នេះជាពេលដែលណាថាន់ប្រាប់ដាវីឌនូវសារពិតពីព្រះអំពីកំហុសរបស់ដាវីឌ។ ណាថាន់បាននិយាយថា៖ «ដាវីឌ នេះជាអ្វីដែលអ្នកបានធ្វើ»។ ដាវីឌចាប់ផ្តើមគិតអំពីអំពើបាបរបស់គាត់។

ដាវីឌនឹកចាំថា នៅរដូវផ្ការីក ពេលស្តេចទាំងអស់ចេញទៅច្បាំង តែដាវីឌសម្រេចចិត្តនៅរាំង។ ដាវីឌបានចាត់ មេទ័ពរបស់លោកគឺលោកយ៉ូអាប់ទៅធ្វើសង្គ្រាមជំនួសវិញ។ នៅល្ងាចថ្ងៃមួយ ពេលដែលដាវីឌដើរជុំវិញ រាជវាំង គាត់បានឃើញស្ត្រីស្អាតម្នាក់នៅក្បែរនោះ។ ដាវីឌក៏ចាត់អ្នកនាំសារម្នាក់ឲ្យនាំស្ត្រីនោះទៅរាជវាំង។

ស្តេចដាវីឌបានប្រព្រឹត្តចំពោះស្ត្រីដ៏ស្រស់ស្អាត ឈ្មោះបាតសេបា នោះដូចជាភរិយារបស់គាត់ដែរ។ គាត់បានរកឃើញថានាងបានរៀបការជាមួយ អ៊ូរី ជាទាហានដែលប្រយុទ្ធក្រោមការបញ្ជារបស់យ៉ូអាប់។ ជំនួសឲ្យការប្រែចិត្តក្នុងការចង់បានប្រពន្ធអ៊ូរី ស្តេចដាវីឌបានផ្ញើសារទៅយ៉ូអាប់ ដោយប្រាប់គាត់ឲ្យដាក់អ៊ូរីនៅសមរភូមិជួរមុខដើម្បីសម្លាប់អ៊ូរីចោល។ ពេលដំណឹងនេះបានដឹង ដល់ដាវីឌថា អ៊ូរី ត្រូវគេសម្លាប់ក្នុងសមរភូមិហើយនោះ គាត់ក៏បានរៀបការជាមួយនាងបាតសេបា។

នៅចាំរឿងនិទានរបស់ណាថាន់ដែរឬទេ? ដាវីឌបានដឹងថា គាត់ក៏ដូចជាបុរសអ្នកមានបានលួចចៀមនោះអីចឹង គាត់ក៏បានលួចប្រពន្ធរបស់អ្នកដទៃដែរ។ គាត់ស្ទើរតែស្លាប់ដោយសារតែគាត់មានការសោកស្តាយចំពោះអ្វីដែលគាត់បានធ្វើ។ គាត់បានសុំការអភ័យទោសពីព្រះ ហើយបានសរសេរ **ទំនុកតម្កើង៥១** ដើម្បីបង្ហាញពីការប្រែចិត្តរបស់គាត់។

យើងទាំងអស់គ្នាបានធ្វើបាប។ ព្រះគម្ពីរប្រាប់ថា យើងទាំងអស់គ្នាខ្វះភាពល្អឥតខ្ចោះ។ យើងទាំងអស់គ្នាមានអំពើបាបដែលយើងត្រូវប្រែចិត្ត។ យើងអាចទូលប្រាប់ព្រះអំពីអំពើបាបរបស់យើង។ នោះគេហៅថាការសារភាពបាប។ ហើយយើងអាចសន្យាជាមួយព្រះថា យើងចង់ធ្វើឲ្យត្រឹមត្រូវ ហើយថាយើងនឹងខំឲ្យអស់ពីសមត្ថភាព ដើម្បីមិនប្រព្រឹត្តអំពើបាបនោះម្តងទៀត។ នោះហៅថាការប្រែចិត្ត។ ពេលយើងសារភាពហើយប្រែចិត្ត យើងអាចប្រាកដថាព្រះទទួលយកការសុំទោសរបស់យើង។ យើងដឹងថា ព្រះបានអត់ទោសឲ្យយើង ដោយសារទ្រង់បានបញ្ជូនព្រះយេស៊ូវឲ្យសុគតជំនួសរាល់អំពើបាបរបស់យើង!

## ៦. សំនួរពិភាក្សា

១. តើនៅក្នុងរឿងនិទានរបស់ហោរាណាថាន់អ្នកមានបានធ្វើអ្វី? *(គាត់បានលួចចៀមតែ១ពីបុរសក្រីក្រម្នាក់ ដើម្បីរៀបចំអាហារពេលល្ងាចសម្រាប់ភ្ញៀវរបស់គាត់ ជំនួសឲ្យការប្រើសត្វរបស់គាត់។ )*
២. តើស្តេចដាវីឌ និងបុរសអ្នកមាននោះមានភាពស្រដៀងគ្នាត្រង់ណា?

*(លួចប្រពន្ធអ្នកផ្សេង ហើយ សម្លាប់ប្តីរបស់នាងនៅក្នុងសង្គ្រាម)*

៣. តើស្តេចដាវីឌបានធ្វើអ្វី ពេលគាត់បានដឹងពីអំពើបាបដែលគាត់បានប្រព្រឹត្ត?
*(គាត់បានសារភាពកំហុស ហើយប្រែចិត្តចំពោះព្រះ)*
៤. តើការប្រែចិត្តមានន័យដូចម្តេច ?

*( សន្យាថាយើងនឹងប្រឹងអស់ពីសមត្ថភាពថា មិនប្រព្រឹត្តអំពើបាបដដែលនោះម្តងទៀតទេ )*
៥. តើយើងអាចប្រាកដថាព្រះអត់ទោសឲ្យយើងដោយរបៀបណា ពេលយើងប្រែចិត្ត?
*( ទ្រង់បានចាត់ ព្រះយេស៊ូវឲ្យមកសុគតសម្រាប់អំពើបាបរបស់យើង )*

**៧. ល្បែងកំសាន្ត «ខ្លែងឆាបកូនមាន់»**



១. បែងចែកកុមារជា ២ក្រុម ឬច្រើនជាងនេះ
២. ក្នុងក្រុមនីមួយៗកុមារត្រូវតោងចង្កេះគ្នា។ អ្នកដែលនៅឈរមុខគេគឺត្រូវតាមចាប់យកអ្នកក្រោយគេនៃក្រុមផ្សេងទៀត ហើយក៏ត្រូវព្យាយាមការពារកូនក្រុមខ្លួនឯងផងដែរ ( កន្ទុយក្រោយគេ )
៣. តាមរយៈល្បែងនេះបានបង្ហាញថា ទោះស្ថិតក្នុងកាលៈទេសៈបែបណាមេមាន់ព្យាយាមការពារកូនរបស់គេ។ ហើយដូចជាព្រះអញ្ចឹងដែរ ព្រះតែងតែការពារនិងអត់ទោសដល់យើងនៅពេលយើងប្រែចិត្តពីអំពើបាប។

**៨. ខគម្ពីរចងចាំ**

**ទំនុកតម្កើង ៥១៖១០** *"ឱព្រះអង្គអើយ សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំ ហើយកែវិញ្ញាណក្នុងទូលបង្គំឲ្យត្រឹមត្រូវឡើង។"*

**៩. ហាត្ថកម្ម «សូមបង្កើតដួងចិត្តបរិសុទ្ធក្នុងទូលបង្គំ»**

សម្ភារៈដែលត្រូវការ៖ រូបបេះដូង កូល័រ និងប៊ិក



១. សូមបោះពុម្ពរូបភាពបេះដូងសម្រាប់កុមារគ្រប់ៗគ្នា
២. សរសេរខគម្ពីរចងចាំ «**ទំនុកតម្កើង ៥១៖១០** *"ឱព្រះអង្គអើយ សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំ ហើយកែវិញ្ញាណ ក្នុងទូលបង្គំឲ្យត្រឹមត្រូវឡើង។"*» នៅចំកណ្តាលបេះដូងនោះ។ ប្រសិនបើកុមារមួយចំនួនមានការពិបាកក្នុងការសរសេរនោះ សូមឲ្យពួកគេសរសេរតែ **"សូមបង្កើតដួងចិត្តបរិសុទ្ធក្នុងទូលបង្គំ"**។
៣. ឲ្យសិស្សផាត់ពណ៌បេះដូង និងដៃ។
៤. សូមរំឭកកុមារថា ព្រះតែងតែអត់ទោសឲ្យយើង ពេលយើងចេះប្រែចិត្តដូចស្តេចដាវីឌ!

**១០. ចំរៀង** *( រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស )*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
អំពើបាបខ័ណ្ឌរវាងព្រះ និងយើង ប៉ុន្តែព្រះយេស៊ូវបានចូលរួមជាមួយយើងម្តងទៀត តាមរយៈការសុគតរបស់ទ្រង់ និងការរស់ឡើងវិញរបស់ទ្រង់។ តាមរយៈព្រះអង្គ យើងមានជីវិតថ្មី និងឱកាសដើម្បី ប្រែចិត្ត ហើយចាប់ផ្តើមម្តងទៀត! សូមអាន**ទំនុកតម្កើង ៥១**។ យើងអាចដឹងពីអារម្មណ៍របស់ដាវីឌ តាមរយៈទំនុករបស់គាត់។ តើលើកចុងក្រោយពេលណា ដែលអ្នកមានវិប្បដិសារីនៃអំពើបាប ហើយ អស់សង្ឃឹមក្នុងការកម្ចាត់វាចោល? អរគុណព្រះយេស៊ូវសម្រាប់ភាពស្រស់ស្អាត ដែលទ្រង់បានញែក យើងចេញពីអំពើបាប។ បើគ្មានការលះបង់របស់ព្រះយេស៊ូវទេ នោះយើងនឹងធ្លាក់ទៅក្នុងអំពើបាបជារៀងរហូត ។

# សូមបង្កើតដួងចិត្តបរិសុទ្ធក្នុងទូលបង្គំ



# សូមបង្កើតដួងចិត្តបរិសុទ្ធក្នុងទូលបង្គំ

